# កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស
# អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# លើកទី ៧

ឈឈ៚៚

អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥

# មាតិកា

១- របាយការណ៍សង្ខេបពីវឌ្ឍនភាព និងសមិទ្ធផល ដែលសម្រេចបានក្នុងខែកក្កដា ឆ្នាំ២០១៥ របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

២- ផែនការសកម្មភាព និង ទិសដៅសម្រាប់អនុវត្តបន្ត

# ១- របាយការណ៍សង្ខេបសកម្មភាពដែលបានអនុវត្ត

- នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំពេញអង្គលើកទី១ សំរាប់ឆ្នាំ២០១៥ ដែលមានសមាជិកអញ្ជើញមកពី គណៈកម្មាធិការអេដស៍ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដៃគូរអភិវឌ្ឍន៍ បញ្ញាញក្រុមប្រឈមមុខខ្ពស់ និងតំណាងអ្នករស់នៅជាមួយមេរោគអេដស៍។ កិច្ចប្រជុំនេះដឹកនាំពិភាក្សាផ្ទាល់ដោយ ឯកឧត្តម **អៀង មួលី** ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយផ្តោតសំខាន់ទៅលើផែនការយុទ្ធសាស្រ្តជាតិលើកទី៤ (២០១៥-២០២០) ដើម្បីរៀបចំសុំការអនុម័តពីប្រមុខរាជរដ្ឋាភិបាល។

- ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៥ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយតំណាងក្រសួងព័ត៌មាន ក្រសួងសង្គមកិច្ច ក្រសួងទេសចរណ៍ សង្គមសីវិល អាជ្ញាធរដែនដី និងតំណាងក្រុមប្រឈមមុខខ្ពស់ បានធ្វើសកម្មភាពចុះស្វែងយល់ និងលើកទឹកចិត្តដល់ក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ដល់សហគមន៍ផ្ទាល់របស់ពួកគេ។ ជាលទ្ធផលយើងឃើញថា ការរើសអើងពីក្រុមគ្រួសារនិងខ្លួនឯងនៅតែជាបញ្ហាចំបងចំពោះក្រុមប្រឈមមុខខ្ពស់

- នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៥ ឯកឧត្តម អគ្គលេខាធិការ បានអញ្ជើញធ្វើបទឧទ្ទេសនាមស្តីពីការរីករាលដាលនៃមេរោគអេដស៍ និងភាពប្រឈមរបស់យុវវ័យដល់ប្អូនៗនិស្សិតនៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ លទ្ធផល យើងឃើញថា ប្អូនៗនិស្សិតមានការយកចិត្តទុកដាក់ស្តាប់ ប្រកបដោយភាពញញឹម ដើម្បីការចូលរួមលុបបំបាត់ការឆ្លងថ្មីនិងការរើសអើងអ្នករស់នៅជាមួយមេរោគអេដស៍។

- នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៥ ឯកឧត្តម **សៀង ម្ចលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអនុញ្ញាតិអោយប្រតិភូសហរដ្ឋអាមេរិក និងតំណាងមកពីថ្នាក់តំបន់ ប្រចាំទីក្រុងបាងកក ជួបពិភាក្សានៅទីស្នាក់ការកណ្តាលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ការពិភាក្សាផ្តោតលើការងារសំខាន់ៗ ដែលសហរដ្ឋអាមេរិកអាចផ្តល់ការគាំទ្រ និងសហប្រតិបត្តិការការងារអេដស៍នៅកម្ពុជា។

- នៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៥ **ឯកឧត្តម តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមកកិច្ចប្រជុំពិភាក្សារវាងបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ និងអាជ្ញាធរមូលដ្ឋានក្នុងរាជធានីភ្នំពេញ ព្រមទាំងតំណាងអង្គការសហប្រជាជាតិ អង្គការដៃគូ សង្គមស៊ីវិល។ គោលបំណងនៃកិច្ចប្រជុំ គឺដើម្បីធ្វើអោយមានប្រសិទ្ធិភាពកាន់តែខ្លាំងចំពោះការប្រយុទ្ធនិងការរីករាលដាលនៃមេរោគអេដស៍។

- បានចូលរួមកិច្ចប្រជុំជាមួយ PR-NCHADS ផ្នែកធ្វើផែនការ និង ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីពិភាក្សា និងបញ្ជាក់ចំពោះ សូចនាករ ទី ២ ដែលនិយាយអំពីការផ្តល់ ប័ណ្ណបញ្ជាក់អត្តសញ្ញាណ គ្រួសារក្រីក្រ ។ ចំពោះសូចនាករនេះ យើងបានពន្យល់ប្រាប់មូលនិធិសកលថា មិនអាចវាស់វែងបានទេ ព្រោះគ្មានថវិកាសំរាប់អនុវត្ត វាជាភារៈកិច្ចរបស់ស្ថាប័នដ៏ទៃ ខាង NAA គ្រាន់តែជាអ្នកសម្របសម្រួល និងស្នើជាយោបល់តែប៉ុណ្ណោះ ។

- បានធ្វើរបាយការណ៍វឌ្ឍនភាពឆមាសទី ១ ឆ្នាំ២០១៥ ជូនទៅ PR-NCHADS ព្រមទាំងធ្វើផែនការយុទ្ធសាស្រ្តជាតិលើកទី៤ និង របាយការណ៍ GARP ២០១៥ បានដាក់ជូនទៅ UNAIDS តាមរយៈOnline រួចហើយ។

- ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ បានរៀបចំលិខិតទៅក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទាដើម្បីលើកសំណើរ ដាក់បញ្ចូលការឧបត្ថម្ភ ដល់គ្រួសារដែលរងគ្រោះដោយមេរោគអេដស៍ / ជម្ងឺអេដស៍ និងក្រីក្របំផុត ចំនួន ១៤000 នាក់ (អង្ករ ២0គ.ក្រសម្រាប់១នាក់ក្នុង១ខែ) ចូលក្នុងគម្រោងផែនការថវិកាជាតិរបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ឆ្នាំ២០១៦ ។

- ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥ រៀបចំកិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានគោលបំណងពិភាក្សារៀបចំរបៀបវារៈសំរាប់កិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់។

## ២- ផែនការសកម្មភាព និង ទិសដៅសម្រាប់ ខែ សីហា ឆ្នាំ២០១៥

- ត្រៀមរៀបចំកិច្ចប្រជុំចម្រុះរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើការងារអេដស៍ (GDJ-TWG on HIV/AIDS) នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៥ ។
- ចូលរួមប្រជុំប្រចាំត្រីមាសជាមួយ PR-NCHADS ស្តីអំពីការពិនិត្យលើរបាយការណ៍ឆមាសទី១ ។
- កែសំរួល និង សំអាតផែនការយុទ្ធស្រ្តជាតិលើកទី ៤ បកប្រែ និង ត្រៀមបោះពុម្ព ។

- ក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ នឹងរៀបចំកិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៥ និងថ្នាក់ក្រោមជាតិ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥។

- ក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ នឹងកំណត់ថ្ងៃយុទ្ធនាការផ្សព្វផ្សាយដើម្បីកាត់បន្ថយការរើសអើង និងម៉ាក់ងាយ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥។

# សូមអរគុណ ចំពោះការ
# យកចិត្តទុកដាក់ស្តាប់